ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)

លេខ....៦៧៧/២១............គ.វ.ក-១៩

ថ្ងៃ...អង្គារ ៦ កើត.......ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី...១៧...... ខែសីហា ឆ្នាំ២០២១

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋ និងពលករ ដែលនៅសេសសល់មិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩) សូមជម្រាបជូនដល់សាធារណជនជ្រាបថា គ.វ.ក-១៩ បាននឹងកំពុងបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋ និងពលករ ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើង នៅទូទាំងប្រទេស ដោយមានការចូលរួមពីបងប្អូនប្រជាពលរដ្ឋក្នុងការមកចាក់វ៉ាក់សាំងកូវីដ-១៩ បានយ៉ាងផុសផុល។ ហេតុមកដល់បច្ចុប្បន្ននេះ គ.វ.ក-១៩ សង្កេតឃើញថា នៅមានប្រជាពលរដ្ឋ និងពលករមួយចំនួនមិនទាន់បានមកចាក់វ៉ាក់សាំងកូវីដ-១៩ នៅឡើយ ដោយមូលហេតុផ្សេងៗ (ជាពលករ ឬប្រជាពលរដ្ឋ ឬនិស្សិតដែលបានវិលត្រឡប់មកពីបរទេស ហើយទើបបានបញ្ចប់ការធ្វើចត្តាឡីស័ក ស្ត្រីទើបសំរាលកូនរួច និងមូលហេតុផ្សេងៗទៀត)។

គ.វ.ក-១៩ សូមរំលឹកផងដែរថា តាមរយៈសេចក្តីជូនដំណឹងលេខ ៥៦៥/២១ គ.វ.ក-១៩ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ គ.វ.ក-១៩ បានរៀបចំទីតាំង នៃមន្ទីរពេទ្យចំនួន២កន្លែង (មន្ទីរពេទ្យព្រះអង្គឌួង និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក) សម្រាប់ចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់បងប្អូនទាំងជនជាតិខ្មែរ រួមទាំងពលករ និងជនបរទេស ដែលនៅសេសសល់មិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ហើយកំពុងរស់នៅក្នុងរាជធានីភ្នំពេញ។ ដោយឡែកបងប្អូនប្រជាពលរដ្ឋ និងពលករ ដែលកំពុងរស់នៅតាមបណ្តាខេត្តនានា សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមទីតាំងដែលកំពុងធ្វើយុទ្ធនាការ ដោយភ្ជាប់ទៅជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសៀវភៅគ្រួសារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ គ.វ.ក-១៩ សូមអំពាវនាវដល់ប្រជាពលរដ្ឋ និងពលករមានអាយុចាប់ពី១៨ឆ្នាំឡើងទាំងអស់ ដែលនៅសេសសល់មិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ សូមអញ្ជើញស្រវាក់ទៅចាក់វ៉ាក់សាំងកូវីដ-១៩ឱ្យបានគ្រប់គ្នាស្របពេលជាមួយរដ្ឋបាលរាជធានី-ខេត្ត កំពុងតែបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅទូទាំងប្រទេស។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ សូមទំនាក់ទំនងទៅអាជ្ញាធរមូលដ្ឋាន ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត ដែលបងប្អូនកំពុងរស់នៅ ឬមកកាន់ គ.វ.ក-១៩ ដើម្បីមានលទ្ធភាពពិនិត្យ និងដោះស្រាយទៅតាមស្ថានភាពជាក់ស្តែង តាមរយៈលេខទូរស័ព្ទខាងក្រោម៖



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ /លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩០៤ ៣៨៥ | ០៨៩ ៩៨០ ៦៦៦ | ០១២ ៧៧៧ ៧៦០ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងវ៉ាក់សាំង៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)**

វេជ្ជ. ឱ្ម វណ្ណឌីន